ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ២៧០ អនក្រ.បក

# អនុក្រឹត្យ

## ស្ដីពី

## ការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការសេដ្ឋកិច្ចនិងធុរកិច្ចឌីជីថល

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្ដីពីការតែងតាំងនិងការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២១/៥៦៤ ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០២១ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាជាតិសេដ្ឋកិច្ចនិងសង្គមឌីជីថល
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងនិងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៥ ស្ដីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រងនិងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

# សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

អនុក្រឹត្យនេះកំណត់អំពីការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការសេដ្ឋកិច្ចនិងធុរកិច្ចឌីជីថល ដែលសរសេរជាអក្សរកាត់ថា **គ.ស.ធ.ឌ.** ដើម្បីជានាប្រសិទ្ធភាពនិងសក្តិសិទ្ធិភាពនៃការបំពេញមុខងារជាសេនាធិការលើការងារបច្ចេកទេសជូនក្រុមប្រឹក្សាជាតិសេដ្ឋកិច្ចនិងសង្គមឌីជីថល ដែលសរសេរជាអក្សរកាត់ថា **ក.ស.ឌ.** នៅក្នុងការដឹកនាំសម្របសម្រួលនិងការជំរុញការកសាងនិងការអភិវឌ្ឍសេដ្ឋកិច្ច ធុរកិច្ច និងសង្គមឌីជីថលនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី២

## តួនាទីនិងភារកិច្ចរបស់ គ.ស.ធ.ឌ.

**មាត្រា២.-**

**គ.ស.ធ.ឌ.**មានតួនាទីនិងភារកិច្ច ដូចខាងក្រោម៖

- រៀបចំគោលនយោបាយ យុទ្ធសាស្ត្រ គោលការណ៍ និងទិសដៅកសាងនិងអភិវឌ្ឍសេដ្ឋកិច្ច ធុរកិច្ច និងសង្គមឌីជីថល តាមដំណាក់កាលនីមួយៗ ដើម្បីដាក់ជូន **ក.ស.ឌ.** ពិនិត្យនិងសម្រេច
- ពិនិត្យ សិក្សា លើកសំណើ និងផ្តល់យោបល់ជូន **ក.ស.ឌ.** លើការរៀបចំ ការកែសម្រួល និង/ឬការធ្វើវិសោធនកម្មច្បាប់និងលិខិតបទដ្ឋានគតិយុត្ត ដែលមានកម្មវិបាកលើការកសាងនិងការអភិវឌ្ឍសេដ្ឋកិច្ច ធុរកិច្ច និងសង្គមឌីជីថល
- រៀបចំនិងជំរុញការអនុវត្តផែនការអភិវឌ្ឍសេដ្ឋកិច្ច ធុរកិច្ច និងសង្គមឌីជីថល ទាំងក្នុងទិដ្ឋភាពនៃការកសាងហេដ្ឋារចនាសម្ព័ន្ធ ធនធានមនុស្ស និងក្របខណ្ឌច្បាប់និងលិខិតបទដ្ឋានគតិយុត្ត ហើយដែលមានវិសាលភាពគ្របដណ្តប់ទាំងវិស័យសាធារណៈនិងវិស័យឯកជន តាមរយៈការធ្វើសុខដុមនីយកម្មនិងអាទិភាវូបនីយកម្មគម្រោងផ្សេងៗ ការជំរុញការប្រើប្រាស់ធនធានក្នុងកម្រិតឧត្តមានុពលនិងការរក្សាបាននូវការប្រកួតប្រជែងដោយស្មើភាព
- រៀបចំផែនការវិនិយោគសាធារណៈប្រចាំឆ្នាំ រយៈពេលមធ្យម និងរយៈពេលវែង ដោយកំណត់អត្តសញ្ញាណនិងអាទិភាពនៃសំណើគម្រោងវិនិយោគសាធារណៈ ស្របតាមផែនការអភិវឌ្ឍសេដ្ឋកិច្ច ធុរកិច្ច និងសង្គមឌីជីថល និងលើកអនុសាសន៍ជូន **ក.ស.ឌ.** ដើម្បីពិនិត្យនិងសម្រេចស្នើសុំការគាំទ្រពីរាជរដ្ឋាភិបាល តាមរយៈយន្តការវិនិយោគរបស់រដ្ឋដែលមានជាធរមាន
- ពិនិត្យនិងសម្រេចលើការកសាងភាពជាដៃគូនិងសហប្រតិបត្តិការក្នុងប្រទេសនិងអន្តរជាតិ សម្រាប់ការកសាងនិងការអភិវឌ្ឍសេដ្ឋកិច្ច ធុរកិច្ច និងសង្គមឌីជីថល
- កៀរគរធនធានហិរញ្ញវត្ថុ ធនធានបច្ចេកទេស និងធនធានមនុស្ស ក្នុងបុព្វហេតុកសាងនិងអភិវឌ្ឍសេដ្ឋកិច្ច ធុរកិច្ច និងសង្គមឌីជីថល
- ជំរុញ លើកទឹកចិត្ត និងគាំទ្រការចូលរួមលើកស្ទួយការកសាងនិងការអភិវឌ្ឍសេដ្ឋកិច្ច ធុរកិច្ច និងសង្គមឌីជីថលពីគ្រប់មជ្ឈដ្ឋាន
- ជំរុញការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្ត ព្រមទាំងគោលនយោបាយ យុទ្ធសាស្ត្រ គោល-ការណ៍ ទិសដៅ កម្មវិធី គម្រោង និងផែនការកសាងនិងអភិវឌ្ឍសេដ្ឋកិច្ច ធុរកិច្ច និងសង្គមឌីជីថលដោយមានយន្តការអនុវត្តប្រកបដោយប្រសិទ្ធភាព

- ជំរុញការតាមដាន ការត្រួតពិនិត្យ និងការវាយតម្លៃការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្ត ព្រមទាំងគោលនយោបាយ យុទ្ធសាស្ត្រ គោលការណ៍ ទិសដៅ កម្មវិធី គម្រោង និងផែនការកសាង និងអភិវឌ្ឍសេដ្ឋកិច្ច ធុរកិច្ច និងសង្គមឌីជីថល ដោយកំណត់សូចនាករសមិទ្ធកម្មគន្លឹះសម្រាប់ការអនុវត្តនេះ ព្រមទាំងកែសម្រួលវិធានការគោលនយោបាយតាមការចាំបាច់និងរៀបចំរបាយការណ៍ជូន **ក.ស.ឌ.** ពិនិត្យនិងសម្រេច
- ដឹកនាំ សម្របសម្រួល និងជំរុញការកសាងហេដ្ឋារចនាសម្ព័ន្ធគាំទ្រដល់ការកសាងនិងការអភិវឌ្ឍសេដ្ឋកិច្ច ធុរកិច្ច និងសង្គមឌីជីថល
- ជំរុញការចែករំលែកទិន្នន័យដើម្បីបង្កើនសហថាមពលនិងសហនវានុវត្តន៍រវាងវិស័យសាធារណៈ និងវិស័យឯកជន សំដៅជំរុញល្បឿននៃការកសាងមូលដ្ឋាន ការចាប់យក និងបរិវត្តកម្មឌីជីថលក្នុងវិស័យសេដ្ឋកិច្ច ធុរកិច្ច និងសង្គមឌីជីថល
- សហការនិងសម្របសម្រួលជាមួយនឹងតួអង្គពាក់ព័ន្ធ សំដៅរួមចំណែកសម្រេចចក្ខុវិស័យ គោលបំណង និងគោលដៅនៃក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ចនិងសង្គមឌីជីថលកម្ពុជា
- បំពេញតួនាទីនិងភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនពីប្រធាន **ក.ស.ឌ.**។

## ជំពូកទី៣
## សមាសភាពរបស់ គ.ស.ធ.ឌ.

**មាត្រា៣.-**

**គ.ស.ធ.ឌ.**មានសមាសភាព ដូចខាងក្រោម៖

| | |
|---|---|
| - រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ប្រធាន |
| - រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | អនុប្រធាន |
| - រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ | អនុប្រធាន |
| - រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម | អនុប្រធាន |
| - រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា | អនុប្រធាន |
| - រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ១រូប | អនុប្រធាន |
| - រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងរ៉ែនិងថាមពល ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងផែនការ ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងព័ត៌មាន ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងយុត្តិធម៌ ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងសុខាភិបាល ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងសាធារណការនិងដឹកជញ្ជូន ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ១រូប | សមាជិក |

- រដ្ឋលេខាធិការក្រសួងទេសចរណ៍ ១រូប សមាជិក
- រដ្ឋលេខាធិការក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ១រូប សមាជិក
- រដ្ឋលេខាធិការក្រសួងមុខងារសាធារណៈ ១រូប សមាជិក
- តំណាងឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ១រូប សមាជិក
- តំណាងធនាគារជាតិនៃកម្ពុជា ១រូប សមាជិក
- តំណាងនិយ័តករនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ១រូបពីនិយ័តករនីមួយៗ សមាជិក
- តំណាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ១រូប សមាជិក
- តំណាងអគ្គនាយកដ្ឋានពន្ធដារ ១រូប សមាជិក
- តំណាងអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ១រូប សមាជិក
- អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន **គ.ស.ធ.ឌ.** សមាជិកអចិន្ត្រៃយ៍។

**គ.ស.ធ.ឌ.**អាចមានសមាសភាពបន្ថែមជាប្រធានស្ថាប័នឬតំណាងក្រសួង-ស្ថាប័នពាក់ព័ន្ធផ្សេងទៀតនៃរាជរដ្ឋាភិបាលតាមការចាំបាច់។

សមាសភាពជាក់ស្តែងនៃ **គ.ស.ធ.ឌ.** ត្រូវតែងតាំងដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

## ជំពូកទី៤
## ការប្រព្រឹត្តទៅរបស់ គ.ស.ធ.ឌ.

**មាត្រា៤.-**

**គ.ស.ធ.ឌ.** ត្រូវប្រជុំរៀងរាល់៣(បី)ខែម្តង តាមការអញ្ជើញរបស់ប្រធាន។ ក្នុងករណីចាំបាច់ ប្រធាន **គ.ស.ធ.ឌ.** អាចកោះប្រជុំជាវិសាមញ្ញបាន។

នៅក្នុងករណីដែលប្រធាន **គ.ស.ធ.ឌ.** អវត្តមានឬមានករណីចាំបាច់ ប្រធាន **គ.ស.ធ.ឌ.** អាចផ្ទេរសិទ្ធិជូនអនុប្រធានណាមួយ ដើម្បីដឹកនាំកិច្ចប្រជុំ។

សមាជិក **គ.ស.ធ.ឌ.** ដែលមិនអាចចូលរួមកិច្ចប្រជុំបាន ត្រូវចាត់ថ្នាក់ដឹកនាំជាន់ខ្ពស់ដែលមានសិទ្ធិសម្រេចក្នុងនាមស្ថាប័នខ្លួនដើម្បីចូលរួមកិច្ចប្រជុំនិងសម្រេចជំនួស។

**មាត្រា៥.-**

ប្រធាន **គ.ស.ធ.ឌ.** ឬអនុប្រធានដែលទទួលសិទ្ធិដឹកនាំកិច្ចប្រជុំពីប្រធាន មានសិទ្ធិអញ្ជើញថ្នាក់ដឹកនាំ មន្ត្រីជាន់ខ្ពស់ តំណាងក្រសួង-ស្ថាប័នពាក់ព័ន្ធ ឬឥស្សរជនដែលមានបទពិសោធ សមត្ថភាព និងជំនាញវិជ្ជាជីវៈ ចូលរួមផ្តល់យោបល់ក្នុងកិច្ចប្រជុំរបស់ **គ.ស.ធ.ឌ.** តាមការចាំបាច់។

**មាត្រា៦.-**

**គ.ស.ធ.ឌ.**មានអគ្គលេខាធិការដ្ឋានមួយជាសេនាធិការ ដែលមានតួនាទីនិងភារកិច្ច ដូចខាងក្រោម៖

- ធ្វើជាសេនាធិការបច្ចេកទេសនិងរដ្ឋបាលជូន **គ.ស.ធ.ឌ.**
- រៀបចំគោលនយោបាយ យុទ្ធសាស្ត្រ គោលការណ៍ និងទិសដៅកសាងនិងអភិវឌ្ឍសេដ្ឋកិច្ច ធុរកិច្ច និងសង្គមឌីជីថល តាមដំណាក់កាលនីមួយៗ ដើម្បីដាក់ជូន **គ.ស.ធ.ឌ.** ពិនិត្យនិងសម្រេច
- ពិនិត្យ សិក្សា លើកសំណើ និងផ្តល់យោបល់ជូន **គ.ស.ធ.ឌ.** លើការរៀបចំ ការកែសម្រួល និង/ឬការធ្វើវិសោធនកម្មច្បាប់និងលិខិតបទដ្ឋានគតិយុត្ត ដែលមានកម្មវិបាកលើការកសាងនិងការអភិវឌ្ឍសេដ្ឋកិច្ច ធុរកិច្ច និងសង្គមឌីជីថល

- ពិនិត្យនិងលើកយោបល់លើគម្រោងនិងផែនការវិនិយោគក្នុងការកសាងនិងការអភិវឌ្ឍសេដ្ឋកិច្ច ធុរកិច្ច និងសង្គមឌីជីថល ប្រចាំឆ្នាំ រយៈពេលមធ្យម និងរយៈពេលវែង ដើម្បីដាក់ជូន **គ.ស.ធ.ឌ.** ពិនិត្យនិងសម្រេច
- កសាងភាពជាដៃគូនិងសហប្រតិបត្តិការក្នុងប្រទេសនិងអន្តរជាតិសម្រាប់ការកសាងនិងការអភិវឌ្ឍសេដ្ឋកិច្ច ធុរកិច្ច និងសង្គមឌីជីថល តាមការសម្រេចរបស់ **គ.ស.ធ.ឌ.**
- កៀរគរធនធានហិរញ្ញវត្ថុ ធនធានបច្ចេកទេស និងធនធានមនុស្ស ក្នុងបុព្វហេតុកសាងនិងអភិវឌ្ឍសេដ្ឋកិច្ច ធុរកិច្ច និងសង្គមឌីជីថល តាមការសម្រេចរបស់ **គ.ស.ធ.ឌ.**
- ជំរុញការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្ត ព្រមទាំងគោលនយោបាយ យុទ្ធសាស្ត្រ គោល-ការណ៍ ទិសដៅ កម្មវិធី គម្រោង និងផែនការកសាងនិងអភិវឌ្ឍសេដ្ឋកិច្ច ធុរកិច្ច និងសង្គមឌីជីថល ដោយមានយន្តការអនុវត្តប្រកបដោយប្រសិទ្ធភាព តាមការសម្រេចរបស់ **គ.ស.ធ.ឌ.**
- ដឹកនាំ សម្របសម្រួល និងជំរុញការកសាងហេដ្ឋារចនាសម្ព័ន្ធគាំទ្រដល់ការកសាងនិងការអភិវឌ្ឍសេដ្ឋកិច្ច ធុរកិច្ច និងសង្គមឌីជីថល តាមការសម្រេចរបស់ **គ.ស.ធ.ឌ.**
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្ត ព្រមទាំងគោល-នយោបាយ យុទ្ធសាស្ត្រ គោលការណ៍ ទិសដៅ កម្មវិធី គម្រោង និងផែនការកសាងនិងអភិវឌ្ឍសេដ្ឋកិច្ច ធុរកិច្ច និងសង្គមឌីជីថល ដោយកំណត់សូចនាករសមិទ្ធកម្មគន្លឹះសម្រាប់ការអនុវត្តនេះ ព្រមទាំងកែសម្រួលវិធានការគោលនយោបាយតាមការចាំបាច់និងរៀបចំរបាយការណ៍ជូន **គ.ស.ធ.ឌ.** ពិនិត្យនិងសម្រេច
- ជំរុញការចែករំលែកទិន្នន័យដើម្បីបង្កើនសហថាមពលនិងសហនវានុវត្តន៍រវាងវិស័យសាធារណៈ និងវិស័យឯកជន សំដៅជំរុញល្បឿននៃការកសាងមូលដ្ឋាន ការចាប់យក និងបរិវត្តកម្មឌីជីថលក្នុងវិស័យធុរកិច្ច សេដ្ឋកិច្ច និងសង្គមឌីជីថល តាមការសម្រេចរបស់ **គ.ស.ធ.ឌ.**
- សហការនិងសម្របសម្រួលជាមួយនឹងតួអង្គពាក់ព័ន្ធសំដៅរួមចំណែកសម្រេចចក្ខុវិស័យ គោល-បំណង និងគោលដៅនៃក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ចនិងសង្គមឌីជីថលកម្ពុជា តាមការសម្រេចរបស់ **គ.ស.ធ.ឌ.**
- ផ្តួចផ្តើម កំណត់កម្មវត្ថុ និងធ្វើការស្រាវជ្រាវ ព្រមទាំងរៀបចំទស្សនកិច្ចសិក្សា ដើម្បីទាញយកបទពិសោធនិងប្រមូលជាតុចូល សំដៅកសាងនិងអភិវឌ្ឍសេដ្ឋកិច្ច ធុរកិច្ច និងសង្គមឌីជីថល តាមការសម្រេចរបស់ **គ.ស.ធ.ឌ.**
- រៀបចំនិងបូកសរុបរបាយការណ៍វឌ្ឍនភាពការងារជូន **គ.ស.ធ.ឌ.** ពិនិត្យនិងសម្រេច
- បំពេញតួនាទីនិងភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនពីប្រធាន **គ.ស.ធ.ឌ.**។

**មាត្រា៧.-**

អគ្គលេខាធិការដ្ឋាន **គ.ស.ធ.ឌ.** មានរចនាសម្ព័ន្ធ ដូចខាងក្រោម៖

- នាយកដ្ឋានរដ្ឋបាល ហិរញ្ញវត្ថុ និងធនធានមនុស្ស
- នាយកដ្ឋានស្រាវជ្រាវ គោលនយោបាយ និងច្បាប់
- នាយកដ្ឋានគម្រោង នវានុវត្តន៍ និងកម្មវិធីអភិវឌ្ឍ
- នាយកដ្ឋានបណ្តុះបណ្តាល ផ្សព្វផ្សាយ និងសហប្រតិបត្តិការ
- នាយកដ្ឋានតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ។

នាយកដ្ឋាននីមួយៗនៃអគ្គលេខាធិការដ្ឋាន **គ.ស.ធ.ឌ.** មានការិយាល័យចំណុះមួយចំនួនតាមការ-ចាំបាច់។ ការរៀបចំនិងការប្រព្រឹត្តទៅរបស់ការិយាល័យចំណុះឱ្យនាយកដ្ឋាននីមួយៗនៃអគ្គលេខាធិការដ្ឋាន **គ.ស.ធ.ឌ.** ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងជាប្រធាន **គ.ស.ធ.ឌ.**។

អង្គការលេខរបស់អគ្គលេខាធិការដ្ឋាន **គ.ស.ធ.ឌ.** ត្រូវបានកំណត់ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា៨.-**

នាយកដ្ឋានរដ្ឋបាល ហិរញ្ញវត្ថុ និងធនធានមនុស្ស បំពេញមុខងារជាសេនាធិការឱ្យអគ្គលេខាធិការដ្ឋាន **គ.ស.ធ.ឌ.** លើការងារធ្វើផែនការ ទទួល ប្រើប្រាស់ ចាត់ចែង ថែទាំ កៀរគរ តាមដាន ត្រួតពិនិត្យ វាយតម្លៃ គ្រប់គ្រង និងអភិវឌ្ឍ ពាក់ព័ន្ធការងាររដ្ឋបាល ហិរញ្ញវត្ថុ សារពើភណ្ឌ ធនធានមនុស្ស និងកិច្ចការទូទៅ ព្រម-ទាំងការងារពាក់ព័ន្ធផ្សេងទៀត តាមការណែនាំរបស់អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន **គ.ស.ធ.ឌ.** ដើម្បីគាំទ្រដល់នាយកដ្ឋានជំនាញផ្សេងទៀតនៃអគ្គលេខាធិការដ្ឋាន **គ.ស.ធ.ឌ.**។

**មាត្រា៩.-**

នាយកដ្ឋានស្រាវជ្រាវ គោលនយោបាយ និងច្បាប់ បំពេញមុខងារជាសេនាធិការឱ្យអគ្គលេខាធិការដ្ឋាន **គ.ស.ធ.ឌ.** លើការងារដឹកនាំ សហការ សម្របសម្រួល ផ្តួចផ្តើម កំណត់កម្មវត្ថុ វិភាគ ពិនិត្យ លើកសំណើ ផ្តល់យោបល់ រៀបចំ គ្រប់គ្រង និងអភិវឌ្ឍ ពាក់ព័ន្ធការស្រាវជ្រាវ គោលនយោបាយ យុទ្ធសាស្ត្រ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ព្រមទាំងការងារពាក់ព័ន្ធផ្សេងទៀត តាមការណែនាំរបស់អគ្គលេខាធិការនៃអគ្គ-លេខាធិការដ្ឋាន **គ.ស.ធ.ឌ.** សំដៅកសាងនិងអភិវឌ្ឍសេដ្ឋកិច្ច ធុរកិច្ច និងសង្គមឌីជីថល។

**មាត្រា១០.-**

នាយកដ្ឋានគម្រោង នវានុវត្តន៍ និងកម្មវិធីអភិវឌ្ឍ បំពេញមុខងារជាសេនាធិការឱ្យអគ្គលេខាធិការដ្ឋាន **គ.ស.ធ.ឌ.** លើការងារដឹកនាំ សហការ សម្របសម្រួល ពិនិត្យ លើកយោបល់ ផ្តួចផ្តើម ជំរុញ ស្រាវជ្រាវ គ្រប់គ្រង និងអភិវឌ្ឍ ពាក់ព័ន្ធគម្រោងបច្ចេកវិទ្យាឌីជីថល នវានុវត្តន៍ ថ្នាលបច្ចេកវិទ្យាឌីជីថល និងកម្មវិធីអភិវឌ្ឍផ្សេងៗ ព្រមទាំងការងារពាក់ព័ន្ធផ្សេងទៀត តាមការណែនាំរបស់អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន **គ.ស.ធ.ឌ.** សំដៅកសាងនិងអភិវឌ្ឍសេដ្ឋកិច្ច ធុរកិច្ច និងសង្គមឌីជីថល។

**មាត្រា១១.-**

នាយកដ្ឋានបណ្តុះបណ្តាល ផ្សព្វផ្សាយ និងសហប្រតិបត្តិការ បំពេញមុខងារជាសេនាធិការឱ្យអគ្គ-លេខាធិការដ្ឋាន **គ.ស.ធ.ឌ.** លើការងារសហការ សម្របសម្រួល ពិនិត្យ រៀបចំ ចែករំលែក គ្រប់គ្រង និងអភិវឌ្ឍ ពាក់ព័ន្ធការបណ្តុះបណ្តាល ការផ្សព្វផ្សាយ និងសហប្រតិបត្តិការជាមួយនឹងតួអង្គពាក់ព័ន្ធ ព្រម-ទាំងការងារពាក់ព័ន្ធផ្សេងទៀត តាមការណែនាំរបស់អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន **គ.ស.ធ.ឌ.** សំដៅកសាងនិងអភិវឌ្ឍសេដ្ឋកិច្ច ធុរកិច្ច និងសង្គមឌីជីថល។

**មាត្រា១២.-**

នាយកដ្ឋានតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ បំពេញមុខងារជាសេនាធិការឱ្យអគ្គលេខាធិការដ្ឋាន **គ.ស.ធ.ឌ.** លើការងារសហការ សម្របសម្រួល ពិនិត្យ រៀបចំ ចែករំលែក ជំរុញ គ្រប់គ្រង និងអភិវឌ្ឍ ពាក់-ព័ន្ធការតាមដាន ការត្រួតពិនិត្យ និងការវាយតម្លៃការអនុវត្តច្បាប់ លិខិតបទដ្ឋានគតិយុត្ត គោលនយោបាយ យុទ្ធសាស្ត្រ គោលការណ៍ ទិសដៅ កម្មវិធី គម្រោង និងផែនការ ព្រមទាំងការងារពាក់ព័ន្ធផ្សេងទៀត តាមការណែនាំរបស់អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន **គ.ស.ធ.ឌ.** សំដៅធានាប្រសិទ្ធភាពនិងសក្តិសិទ្ធិភាពនៃការកសាងនិងការអភិវឌ្ឍសេដ្ឋកិច្ច ធុរកិច្ច និងសង្គមឌីជីថល។

**មាត្រា១៣.-**

អគ្គលេខាធិការដ្ឋាន **គ.ស.ធ.ឧ.** ត្រូវដឹកនាំដោយអគ្គលេខាធិការ១(មួយ)រូបជាថ្នាក់ដឹកនាំជាន់ខ្ពស់នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អមដោយអគ្គលេខាធិការរងមួយចំនួន។ អគ្គលេខាធិការនិងអគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋាន **គ.ស.ធ.ឧ.** ត្រូវតែងតាំងដោយព្រះរាជក្រឹត្យ។

នាយកដ្ឋាននីមួយៗនៃអគ្គលេខាធិការដ្ឋាន **គ.ស.ធ.ឧ.** ត្រូវដឹកនាំដោយប្រធាន១(មួយ)រូប អម-ដោយអនុប្រធានមួយចំនួនជាជំនួយការ។

ប្រធាននាយកដ្ឋាននីមួយៗនៃអគ្គលេខាធិការដ្ឋាន **គ.ស.ធ.ឧ.** ត្រូវតែងតាំងឬផ្លាស់ប្តូរភារកិច្ចដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងជាប្រធាន **គ.ស.ធ.ឧ.**។ ការតែងតាំងឬការផ្លាស់ប្តូរភារកិច្ចមន្ត្រីចាប់ពីថ្នាក់ក្រោមប្រធាននាយកដ្ឋាននីមួយៗនៃអគ្គលេខាធិការដ្ឋាន **គ.ស.ធ.ឧ.** ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងជាប្រធាន **គ.ស.ធ.ឧ.** តាមសំណើរបស់អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន **គ.ស.ធ.ឧ.**។

**មាត្រា១៤.-**

មន្ត្រីរបស់អគ្គលេខាធិការដ្ឋាន **គ.ស.ធ.ឧ.** រួមមានមន្ត្រីរាជការក្នុងក្របខណ្ឌមុខងារសាធារណៈនិងមន្ត្រីជាប់កិច្ចសន្យា។

ការជ្រើសរើសមន្ត្រីជាប់កិច្ចសន្យាសម្រាប់ជួយការងារអគ្គលេខាធិការដ្ឋាន **គ.ស.ធ.ឧ.** តាមតម្រូវការជាក់ស្តែង ត្រូវមានការឯកភាពពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងជាប្រធាន **គ.ស.ធ.ឧ.** តាមសំណើរបស់អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន **គ.ស.ធ.ឧ.**។

**មាត្រា១៥.-**

អគ្គលេខាធិការដ្ឋាន **គ.ស.ធ.ឧ.** អាចមានទីប្រឹក្សាជាអ្នកជំនាញការជាតិនិង/ឬអ្នកជំនាញការអន្តរជាតិមួយចំនួន ដែលមកពីដៃគូអភិវឌ្ឍន៍ ស្ថាប័នស្រាវជ្រាវ ស្ថាប័នអប់រំ និងវិស័យឯកជន សម្រាប់ជួយការងារតាមតម្រូវការជាក់ស្តែង។ ទីប្រឹក្សាអគ្គលេខាធិការដ្ឋាន **គ.ស.ធ.ឧ.** ត្រូវតែងតាំងដោយសេចក្តីសម្រេចរបស់ប្រធាន **គ.ស.ធ.ឧ.** តាមសំណើរបស់អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន **គ.ស.ធ.ឧ.**។

**មាត្រា១៦.-**

បៀវត្សនិងប្រាក់បន្ទាប់បន្សំនៃបៀវត្សសម្រាប់មន្ត្រីជាប់កិច្ចសន្យា ទីប្រឹក្សា និងប្រាក់បំណាច់បន្ថែមរបស់មន្ត្រីរាជការក្នុងក្របខណ្ឌមុខងារសាធារណៈ ដែលបំពេញការងារនៅក្នុងអគ្គលេខាធិការដ្ឋាន **គ.ស.ធ.ឧ.** ត្រូវកំណត់ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងជាប្រធាន **គ.ស.ធ.ឧ.** តាមសំណើរបស់អគ្គ-លេខាធិការនៃអគ្គលេខាធិការដ្ឋាន **គ.ស.ធ.ឧ.**។

**មាត្រា១៧.-**

**គ.ស.ធ.ឧ.**មានសិទ្ធិប្រើប្រាស់ត្រាដោយឡែក ដែលត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធាន **គ.ស.ឧ.** សម្រាប់បំពេញតួនាទីនិងភារកិច្ចរបស់ខ្លួន។

## ជំពូកទី៥

## ប្រភពធនធានរបស់ គ.ស.ធ.ឧ.

**មាត្រា១៨.-**

ថវិកាសម្រាប់ដំណើរការរបស់អគ្គលេខាធិការដ្ឋាន **គ.ស.ធ.ឧ.** ត្រូវគាំទ្រដោយថវិកាជាតិក្នុងគម្រោងថវិកាកម្មវិធីរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**គ.ស.ធ.ឧ.** មានសិទ្ធិទទួល ប្រើប្រាស់ និងចាត់ចែងធនធាននិងមូលនិធិដែលបានមកពីប្រភពស្របច្បាប់ផ្សេងទៀត តាមនីតិវិធីច្បាប់ជាធរមាន សម្រាប់ដំណើរការការងាររបស់ខ្លួន។

## ជំពូកទី៦
## អវសានប្បញ្ញត្តិ

**មាត្រា១៩.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា២០.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ៧កើត ខែកត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១១ ខែវិច្ឆិកា ឆ្នាំ២០២១

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២០
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធ

នៃអនុក្រឹត្យលេខ ២៧០ អនក្រ.បក ចុះថ្ងៃទី ១១ ខែ កត្តិក ឆ្នាំ ២០២១

ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់

គណៈកម្មាធិការសេដ្ឋកិច្ចនិងធុរកិច្ចឌីជីថល (គ.ស.ធ.ឌ.)

## អង្គការលេខរបស់អគ្គលេខាធិការដ្ឋាន គ.ស.ធ.ឌ.

